# ភទ្រឃដភេទកជាតក

## (ច្បាប់ឆដ្ឋសង្គាយនាថា សុរាឃដជាតក)




*ព្រះសាស្ដា កាលស្ដេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធក្មួយរបស់អនាថបិណ្ឌិកសេដ្ឋី បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **សព្ពកាមទទំ កុម្ភំ** *ដូច្នេះជាដើម ។*

*បានឮមកថា ក្មួយអនាថបិណ្ឌិកសេដ្ឋីនោះ បានធ្វើប្រាក់ ៤០ កោដិ អំពីសម្នាក់មាតាបិតាឲ្យវិនាស ដោយសេចក្ដីវិនាសព្រោះផឹកសុរា ហើយក៏ទៅកាន់សម្នាក់លោកសេដ្ឋី ។ សូម្បីលោកសេដ្ឋីក៏បានឲ្យប្រាក់ដល់គេ ១០០០ ដោយពោលថា អ្នកចូរធ្វើជំនួញចុះ ។ ចំណែកក្មួយនោះ ធ្វើប្រាក់ ១០០០ ឲ្យវិនាស ហើយមកម្ដងទៀត ។ អនាថបិណ្ឌិកសេដ្ឋីឲ្យប្រាក់ ៥០០ ដល់គេម្ដងទៀត សូម្បីគេក៏បានធ្វើទ្រព្យនោះឲ្យវិនាស ហើយមកសូមទៀត លោកសេដ្ឋីឲ្យ*

សំពត់សាច់គ្រើមដល់គេ ។ គេធ្វើសំពត់នោះឲ្យវិនាសហើយ មកទៀត អនាថបិណ្ឌិកសេដ្ឋីក៏ឲ្យអ្នកបម្រើចាប់ក្មួយនោះត្រង់ក នាំចេញទៅ ។ គេនោះជាក្លាយជាមនុស្សអនាថា រស់នៅអាស្រ័យនឹងជញ្ជាំងផ្ទះអ្នកដទៃ ហើយក៏ធ្វើបានកាលកិរិយាទៅ មនុស្សទាំងឡាយអូសគេយកទៅចោលខាងក្រៅស្រុក ។ អនាថបិណ្ឌិកសេដ្ឋីទៅកាន់វិហារ ហើយប្រាប់ការប្រព្រឹត្តទៅរបស់ក្មួយនោះទាំងអស់ ដល់ព្រះតថាគត ។ ព្រះសាស្តាត្រាស់ថា តើអ្នកនឹងក្មួយនោះឆ្អែតដូចម្តេចកើត ក្នុងកាលមុន តថាគតសូម្បីឲ្យក្អមដែលអាចឲ្យសេចក្តីប្រាថ្នាគ្រប់យ៉ាងហើយ ក៏នៅតែមិនអាចនឹងញ៉ាំងបុគ្គលនោះឲ្យឆ្អែតបានដែរ កាលអនាថបិណ្ឌិកសេដ្ឋីសូមអង្វរហើយ ព្រះអង្គនាំយកអតីតនិទានមកថា ៖

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលសេដ្ឋី កាលបិតាធ្វើកាលកិរិយាកន្លងទៅហើយ លោកក៏បានតំណែងជាសេដ្ឋី ។ ក្នុងផ្ទះរបស់ព្រះពោធិសត្វនោះ មានទ្រព្យ ៤០ កោដិ កប់ទុកក្នុងដី ហើយលោកមានបុត្រតែមួយប៉ុណ្ណោះ ។ ព្រះពោធិសត្វធ្វើបុណ្យទាំងឡាយមានការឲ្យទានជាដើម កាលធ្វើកាលកិរិយាទៅ លោកបានកើតជាសក្កទេវរាជ ។

លំដាប់នោះ បុត្ររបស់លោកបិទបាំងផ្លូវ ឲ្យគេកសាងមណ្ឌប ជាអ្នកមានមហាជនចោមរោម អង្គុយ ប្រារព្ធផឹកសុរា ។ បុត្រនោះឲ្យទ្រព្យមួយពាន់ៗ ដល់អ្នកធ្វើការលោត អ្នកលេងរបាំ អ្នករាំ និងអ្នកច្រៀងជាដើម ដល់ភាពជាអ្នកលេងស្រី លេងស្រា និងលេងសាច់ជាដើម មានសេចក្តីត្រូវការតែមហោស្រពប៉ុណ្ណោះថា ការច្រៀងក្នុងទីណា ការរាំក្នុងទីណា ការប្រគំក្នុងទីណា ជាមនុស្សប្រមាទប្រព្រឹត្តទៅ ។ មិនយូរប៉ុន្មាន គេធ្វើទ្រព្យ ៤០ កោដិ និងគ្រឿងឧបភោគបរិភោគឲ្យវិនាសអស់ ក្លាយជាមនុស្សទុគ៌ត កំព្រាអនាថា ស្លៀកសំពត់ចាស់ ប្រព្រឹត្តទៅ ។

ស្តេចសក្កៈ កាលពិចារណា បានដឹងភាពទុគ៌តរបស់បុរសនោះហើយ យាងមកដោយសេចក្តីស្រឡាញ់កូន រួចក៏ឲ្យក្អមដែលអាចឲ្យសេចក្តីប្រាថ្នាគ្រប់យ៉ាង និងប្រៀនប្រដៅថា នែ

កូន ក្អមនេះមិនបែកយ៉ាងណា អ្នកចូររក្សាយ៉ាងនោះ កាលអ្នកមានក្អមនេះ ឈ្មោះថា ការកំណាត់នៃទ្រព្យ នឹងមិនមានឡើយ ចូរអ្នកកុំប្រមាទ ដូច្នេះហើយ លោកក៏យាងទៅកាន់ទេវលោកវិញ ។ ចាប់ពីពេលនោះមក បុរសនោះតែងតែផឹកសុរា ហើយប្រព្រឹត្តទៅ ។

ថ្ងៃមួយ បុរសនោះមានសេចក្តីប្រមាទ បោះក្អមទៅលើអាកាសហើយទទួល ក៏ភ្លាត់ម្តង ធ្វើឲ្យក្អមធ្លាក់លើដី បែកខ្ទេច ។ តាំងពីពេលនោះមក គេក៏ក្លាយជាមនុស្សក្រីក្រម្តងទៀត ស្លៀកសំពត់ចាស់ មានដៃកាន់អំបែង ត្រាច់រកអាហារ អាស្រ័យនឹងជញ្ជាំងផ្ទះអ្នកដទៃ ហើយក៏ធ្វើកាលកិរិយាទៅ ។

ព្រះសាស្តានាំអតីតនិទាននេះមកហើយ ទ្រង់ត្រាស់ថា

**សព្ពកាមទទំ កុម្ភំ, កុដំ លទ្ធាន ធុត្តកោ;**
**យាវ ធំ អនុបាលេតិ, តាវ សោ សុខមេធតិ។**

អ្នកលេងបាននូវឆ្នាំងកំណាប់ ដែលឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ហើយរក្សាឆ្នាំងនោះដរាបណា អ្នកលេងនោះ ក៏ដល់នូវសេចក្តីសុខ ដរាបនោះ ។

**យទា មត្តោ ច ទិត្តោ ច, បមាទា កុម្ភមព្ភិទា;**
**តទា នគ្គោ ច ពោត្តោ ច, បច្ឆា ពាលោ វិហញ្ញតិ។**

ក្នុងកាលណា អ្នកលេងស្រវឹងផង គឃ្លើនផង បានបំបែកឆ្នាំង ព្រោះសេចក្តីប្រមាទ ក្នុងកាលនោះ បុគ្គលពាលទៅជាមនុស្សអាក្រាតផង ជាអ្នកស្លៀកកំណាត់សំពត់កន្ទបផង រមែងក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ ។

**ឯវមេវ យោ ធនំ លទ្ធា, បមត្តោ បរិភុញ្ជតិ;**
**បច្ឆា តប្បតិ ទុម្មេធោ, កុដំ ភិត្វាវ ធុត្តកោ។**

*បុគ្គលឥតប្រាជ្ញា បាននូវទ្រព្យយ៉ាងនេះហើយ ជាអ្នកមានសេចក្តីប្រមាទប្រើប្រាស់ រមែងក្តៅក្រហាយ ក្នុងកាលខាងក្រោយ ដូចជាអ្នកលេង (ដែលក្តៅក្រហាយស្តាយក្រោយ) ព្រោះតែបំបែកឆ្នាំងចោល ។*

*បណ្តាបទទាំងនោះ បទថា* **សព្ពកាមទទំ** *សេចក្តីថា ក្អមដែលអាចឲ្យវត្ថុកាម គ្រប់យ៉ាង ។ បថា* **កុដំ** *បានដល់ ជាពាក្យវេវចនៈរបស់កុម្ភៈ ។ បទថា* **យាវ** *បានដល់ អស់កាលត្រឹមណា ។ បទថា* **អនុបាលេតិ** *សេចក្តីថា បុគ្គលណាបានក្អមដែលមានសភាពបែបនោះ ហើយរក្សាបានដរាបណា បុគ្គលនោះក៏ដល់នូវសេចក្តីសុខ ដរាបនោះ ។ បទថា* **មត្តោ ច ទិត្តោ ច** *សេចក្តីថា ប្រមាទដោយការស្រវឹងសុរា និងគឃ្នើនដោយការក្រអឺតក្រទម ។ បទថា* **បមាទា កុម្ភមព្ភិទា** *សេចក្តីថា បំបែកឆ្នាំង ដោយសេចក្តីប្រមាទ ។ បទថា* **នគ្គោ ច ចោត្តោ ច** *សេចក្តីថា គ្រាខ្លះ អាក្រាតកាយ គ្រាខ្លះបិទបាំងដោយស្លៀកសំពស់សម្បកឆ្មៃ និងសំពត់ចាស់ ។ បទថា* **ឯវមេវ** *កាត់បទជា ឯវំ ឯវ ។ បទថា* **បមត្តោ** *សេចក្តីថា ដោយសេចក្តីប្រមាទ ។ បទថា* **តប្បតិ** *សេចក្តីថា រមែងសោក ។*

*ព្រះសាស្តាត្រាស់អភិសម្ពុទ្ធគាថាទាំងនេះហើយ ទ្រង់ប្រជុំជាតកថា*

**តទា សុរាឃដភេទកោ ធុត្តោ សេដ្ឋិភាគិនេយ្យោ អហោសិ** *អ្នកលេងដែលធ្វើឲ្យក្អមសុរាបែកក្នុងកាលនោះ បានមកជា ក្មួយរបស់សេដ្ឋី ។*

**សក្កោ បន អហមេវ អហោសិំ** *ចំណែកសក្កទេវរាជ គឺ តថាគត នេះឯង ។*

*កទ្រុយជភេទកជាតក ចប់ ។*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក តិកនិបាត កុម្ភវគ្គ បិដកលេខ ៥៨ ទំព័រ ១៧៦)*

*ថ្ងៃ អង្គារ ១១ រោច ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធិស័ក ព.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ០៧ ខែ សីហា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ*